# សេចក្តីថ្លែងការណ៍រួម
# សូមធានាឱ្យមានយុត្តិធម៌ សម្រាប់ករណីឃាតកម្មលើអ្នកសារព័ត៌មានម្នាក់ នៅខេត្តសៀមរាប

**ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤**

យើងខ្ញុំជាក្រុមសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម ពិតជាមានការតក់ស្លុតយ៉ាងខ្លាំង ចំពោះករណីឃាតកម្មលើលោក ឈឿង ឈឹង អ្នកសារព័ត៌មាននៃអង្គភាព កម្ពុជាអភិវឌ្ឍន៍ ដែលធ្លាប់រាយការណ៍អំពីបទល្មើសព្រៃឈើ ត្រូវបានបាញ់សម្លាប់ក្នុងខេត្តសៀមរាប។

លោក ឈឹង ដែលមានវ័យ ៦៣ឆ្នាំ ត្រូវបានជនសង្ស័យបាញ់ចំត្រូវពោះ បណ្ដាលឱ្យរងរបួសធ្ងន់ នៅថ្ងៃទី៤ ខែធ្នូ ខណៈគាត់កំពុងធ្វើដំណើរតាមផ្លូវស្ថិតក្នុងស្រុកជីក្រែង ខេត្តសៀមរាប។ ដំបូងគាត់ត្រូវបានបញ្ជូនទៅកាន់មណ្ឌលសុខភាពឃុំ ហើយក្រោយមកក៏បានបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកខេត្ត ជាកន្លែងដែលគាត់បានទទួលការវះកាត់នៅថ្ងៃទី៥ ខែធ្នូ។ ប៉ុន្តែគួរឱ្យសោកស្ដាយ លោក ឈឹង ត្រូវបានស្លាប់នៅទាបភ្លឺព្រឹកថ្ងៃទី៧ ខែធ្នូ។ អាជ្ញាធរបានចេញ សេចក្ដីប្រកាសព័ត៌មានមួយ ដោយប្រកាសថាពួកគេបានចាប់ខ្លួនជនសង្ស័យម្នាក់ដែលត្រូវបានគេរាយការណ៍ថាបានសារភាពថាការបាញ់ប្រហារមកលើ លោក ឈឹង ដោយសារតែទំនាស់បុគ្គល។

នេះជាករណីឃាតកម្មលើកដំបូងលើអ្នកសារព័ត៌មាននៅកម្ពុជា ចាប់តាំងពីឆ្នាំ២០១៤ មក នៅពេលដែលលោក តាំង ទ្រី ត្រូវបានសម្លាប់ខណៈកំពុងរាយការណ៍អំពីការកាប់ឈើខុសច្បាប់ដូចគ្នានេះ តែយ៉ាងណា ករណីរំលោភបំពានលើអ្នកសារព័ត៌មាន ដែលបានកត់ត្រា ក្នុងឆ្នាំ២០២៤ បានកើនឡើង បើធៀបនឹងឆ្នាំ២០២៣។ ដូច្នេះយើងខ្ញុំសូមស្នើដល់រាជរដ្ឋាភិបាល សូមធានាថា សិទ្ធិរបស់អ្នកសារព័ត៌មានត្រូវបានការពារ។ ការគាបសង្កត់ភាគច្រើនបានសំដៅទៅលើអ្នកសារព័ត៌មានដែលរាយការណ៍ពីបញ្ហារសើប ដូចជាការបំផ្លិចបំផ្លាញបរិស្ថាន ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងឧក្រិដ្ឋកម្មក្នុងប្រទេស។

អ្នកសារព័ត៌មានត្រូវការសេរីភាពក្នុងការរាយការណ៍ពីការពិតដោយមិនមានការសងសឹក។ ឃាតកម្មដ៏រន្ធត់នេះ ត្រូវបានគេមើលឃើញថា កើតឡើងបន្ទាប់ពីអ្នកសារព័ត៌មានជារឿយៗរងនូវការគំរាមកំហែងនិងការចាប់ដាក់ពន្ធនាគារ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជារឿយៗឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន តែងតែមិនត្រូវបានផ្តន្ទាទោស ដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មានក្នុងប្រទេស ដែលបន្ថែមពីលើករណីថ្មីៗមួយចំនួនដូចជាការបិទស្ថាប័នសារព័ត៌មាន ដឺ ខេមបូឌា ដេលី ក្នុងឆ្នាំ ២០១៧ និងវិទ្យុសំឡេងប្រជាធិបតេយ្យ វីអូឌី នៅឆ្នាំ ២០២៣ និងការបង្ខំលក់ស្ថាប័នសារព័ត៌មានភ្នំពេញប៉ុស្តិ៍ នៅឆ្នាំ២០១៨។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះកម្ពុជាបានបន្តធ្លាក់ចុះរហូតដល់ទៅ៩លេខ ក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ដោយឈរនៅលេខរៀងទី១៥១ ក្នុងចំណោម ១៨០ប្រទេស។

គ្មានអ្នកសារព័ត៌មានណាម្នាក់សមនឹងប្រឈមនឹងសេចក្តីស្លាប់ ដោយសារការងារសារព័ត៌មានរបស់ពួកគេនោះទេ ទោះបីជាពួកគេទាំងនោះធ្វើការឱ្យស្ថាប័នសារព័ត៌មានណាមួយក៏ដោយ ហើយយើងខ្ញុំសូមថ្កោលទោសយ៉ាងដាច់អហង្ការចំពោះអ្នកដែលប្រើអំពើហិង្សា ដើម្បីបំបិទមាត់អ្នកសារព័ត៌មាន។ ការងារសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាសង្គមនេះ មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងពិភពលោក ជាពិសេសនៅក្នុងប្រទេសដែលពោរពេញដោយព័ត៌មានមិនពិត ដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល និងឥស្សរជនជាន់ខ្ពស់។

យើងខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវធានាថាយុត្តិធម៌ត្រូវតែទទួលបានសម្រាប់លោក ឈឹង ដើម្បីបង្ហាញថាការ បង្កបទឧក្រិដ្ឋទៅលើអ្នកសារព័ត៌មានដែលបំពេញការងាររបស់ពួកគេ នឹងមិនត្រូវបានអត់ឱនឡើយនៅក្នុងប្រទេសកម្ពុជា៕

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

1. Overseas Press Club of Cambodia (OPCC)
2. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
3. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
4. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
5. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
6. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
7. Alliance of Independent Journalist (AJI) Indonesia
8. Gerakan Media Merdeka (Geramm)
9. Prachatai (Thailand)
10. National Union of Journalists of the Philippines
11. Association Journalists Timor-Leste (AJTL)
12. International Federation of Journalists (IFJs)
13. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF)
14. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)